State of Oregon
Employment Department

# បទបញ្ជាបណ្ដោះអាសន្នរបស់នាយកដ្ឋានការងារសម្រាប់ភាពអាចបត់បែនបានសម្រាប់អត្ថប្រយោជន៍ធានារ៉ាប់រងភាពគ្មានការងារធ្វើ

នៅថ្ងៃទី 8 ខែមីនា ឆ្នាំ 2020, អភិបាលរដ្ឋលោកស្រី ប្រោន Brown បានចេញបទបញ្ជានីតិប្រតិបត្តិលេខ No. 20-03 ដែលប្រកាសអាសន្ន
ទូទាំងរដ្ឋ ដោយសារតែការឆ្លងវីរុសកូរូណាថ្មី។
ចាប់តាំងពីពេលនោះមកផលប៉ះពាល់ពីវីរុសនិងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការរាលដាលរបស់វាមានផលប៉ះពាល់កាន់តែខ្លាំងឡើងដល់កម្មករនិងស្ថាប័នជំនួញនៅរដ្ឋអូរីហ្គោន Oregon។ ប្រព័ន្ធធានារ៉ាប់រងភាពគ្មានការងារធ្វើ
មានគោលបំណងជួយកម្មករនិងស្ថាប័នជំនួញ និងសហគមន៍ដែលពួកគេកំពុងរស់នៅក្នុងអំឡុងពេលមានការងារដែលរំខាន។
បទបញ្ជានេះដាក់ចេញនូវបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រងភាពគ្មានការងារធ្វើដែលត្រូវអនុវត្តចំពោះស្ថានភាពពិសេស
ដែលកើតឡើងដោយសារតែវីរុស COVID-19 និងវិធានការនានាដើម្បីកាត់បន្ថយការរីករាលដាលរបស់វា។
លើកលែងតែមានការផ្តល់ជូនតាមរបៀបផ្សេងទៀត
ទើបបទប្បញ្ញត្តិនៃវិធាននេះត្រូវអនុវត្តមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទពីមុនរហូតដល់ថ្ងៃទី 8 ខែមីនា ឆ្នាំ 2020
នៅពេលមានប្រកាសអាសន្ននៅទូទាំងរដ្ឋ។

(1) ស្ថានភាពដូចខាងក្រោមនេះ ត្រូវបានគេចាត់ទុកថាជា “ស្ថានភាពដែលទាក់ទងនឹងវីរុស COVID-19”៖

(a) ប្រជាពលរដ្ឋមិនអាចធ្វើការបានទេ ដោយសារពួកគេឈឺដោយសារការឆ្លងវីរុសកូរូណាថ្មីនេះ;

(b) ប្រជាពលរដ្ឋមិនអាចធ្វើការបានទេ ដោយសារពួកគេអាចប៉ះពាល់ជាសក្តានុពលចំពោះវីរុសកូរូណាថ្មីនេះ ហើយត្រូវបានគេកំណត់
រយៈពេលឱ្យស្ថិតនៅដាច់ដោយឡែកពីគ្នាតាមបទបញ្ជា;

(c) ប្រជាពលរដ្ឋមិនអាចធ្វើការបានទេ ដោយសារពួកគេទទួលបានការណែនាំពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ ឬតាមការផ្តល់ដំបូន្មានដែលចេញដោយមន្ត្រីសុខាភិបាលរដ្ឋ ដើម្បីស្ថិតនៅដាច់ដោយឡែកពីគ្នាដោយខ្លួនឯង ដោយសារតែហានិភ័យដែលអាចកើតមានពីការប៉ះពាល់ឬការរីករាលដាលវីរុសកូរូណាថ្មីនេះ;

(d) ប្រជាពលរដ្ឋមិនអាចធ្វើការបានទេ ដោយសារនិយោជករបស់ពួកគេបានបញ្ឈប់ឬកាត់បន្ថយប្រតិបត្តិការ ដោយសារតែការឆ្លងវីរុស
កូរូណាថ្មីនេះ
ដែលរួមមានការបិទឬការកាត់បន្ថយដោយផ្អែកលើការណែនាំឬការផ្តល់ដំបូន្មានរបស់អភិបាលរដ្ឋឬមន្ត្រីសុខាភិបាលរដ្ឋ។

(e) ប្រជាពលរដ្ឋមិនអាចធ្វើការបានទេ
ដោយសារពួកគេត្រូវស្ថិតនៅផ្ទះដើម្បីមើលថែទាំសមាជិកគ្រួសារឬមនុស្សផ្សេងទៀតដែលពួកគេរស់នៅជាមួយ ឬសម្រាប់អ្នកដែលពួកគេត្រូវផ្តល់ជូនការមើលថែទាំអ្នកដែលកំពុងទទួលរងពីការឆ្លងវីរុសកូរូណាថ្មី ឬកំណត់នៅដាច់ដោយឡែកពីគ្នាតាមបទបញ្ជា;

(f) ប្រជាពលរដ្ឋមិនអាចធ្វើការបានទេ ដោយសារពួកគេត្រូវស្ថិតនៅផ្ទះដើម្បីមើលថែទាំកូន ដោយសារការបិទសាលារៀន អ្នកផ្តល់សេវាថែទាំកុមារ ឬកន្លែងស្រដៀងគ្នាផ្សេងទៀត ដោយសារការឆ្លងវីរុសកូរូណាថ្មីនេះ និង

(g) ប្រជាពលរដ្ឋត្រូវបានគេស្នើសុំឱ្យធ្វើការក្នុងករណីអាចមានតម្រូវការទាមទារពួកគេដើម្បីបំពេញមុខងារចំពោះការរំលោភបំពានលើការស្ថិតនៅដាច់ដោយឡែកពីគ្នាតាមបទបញ្ជាឬសេចក្តីណែនាំរបស់អភិបាលរដ្ឋដែលពាក់នឹងការកំណត់លក្ខខណ្ឌនៃសកម្មភាពនានា ដើម្បីកំណត់ការរីករាលដាលនៃការឆ្លងវីរុសកូរូណាថ្មីនេះ។

(2) <u>ការដកសិទ្ធិពីអត្ថប្រយោជន៍ធានារ៉ាប់រងភាពគ្មានការងារធ្វើ។</u>
ប្រជាពលរដ្ឋមិនត្រូវបានគេដកសិទ្ធិពីការទទួលបានអត្ថប្រយោជន៍
ធានារ៉ាប់រងភាពគ្មានការងារធ្វើក្រោមស្ថានភាពដូចខាងក្រោម
(ទោះបីជាពួកគេនៅតែត្រូវបំពេញតាមតម្រូវការទាមទារស្តីពីភាពមានសិទ្ធិស្របច្បាប់ប្រចាំសប្តាហ៍
ដើម្បីទទួលបានអត្ថប្រយោជន៍ក៏ដោយ)៖

(a) ប្រជាពលរដ្ឋត្រូវបានគេឱ្យចេញពីកាងារ ដោយសារតែស្ថានភាពដែលទាក់ទងនឹងវីរុស COVID-19 (ORS 657.176(2)(b));

(b) ប្រជាពលរដ្ឋចាកចេញពីកាងារ ដោយសារតែស្ថានភាពដែលទាក់ទងនឹងវីរុស COVID-19 (ORS 657.176(2)(c));

(c) ប្រជាពលរដ្ឋខកខានដាក់ពាក្យសុំការងារនៅពេលត្រូវបានបញ្ជូនដោយការិយាល័យការងារឬនាយក ដោយសារតែស្ថានភាពដែលទាក់ទងនឹងវីរុស COVID-19 (ORS 657.176(2)(d)); ឬ

(d) ប្រជាពលរដ្ឋខកខានទទួលយកការផ្តល់ជូនការងារ ដោយសារតែស្ថានភាពដែលទាក់ទងនឹងវីរុស COVID-19 (ORS 657.176(2)(f));

(3) <u>មានសមត្ថភាពធ្វើការ</u>– ORS 657.155(1)(c) ហើយច្បាប់សហព័ន្ធតម្រូវឱ្យប្រជាពលរដ្ឋអាចធ្វើការ
ដើម្បីទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងភាពគ្មានការងារធ្វើ។

(a) ប្រជាពលរដ្ឋមិនត្រូវបានគេចាត់ទុកថា មិនអាចមានសមត្ថភាពធ្វើការបានទេ ដោយសារ៖

(A) ពួកគត្រូវស្ថិតនៅដាច់ដោយឡែកពីគ្នាដោយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ ឬតាមការផ្តល់ដំបូន្មានដែលចេញដោយមន្ត្រី

សុខាភិបាលរដ្ឋ ដើម្បីស្ថិតនៅដាច់ដោយឡែកពីគ្នាដោយខ្លួនឯង ដោយសារតែហានិភ័យដែលអាចកើតមានពីការប៉ះពាល់ឬ ការរីករាលដាលវីរុសកូរូណាថ្មីនេះ ប៉ុន្តែពួកគេមិនឈឺឡើយ;

(B) ពួកគេនឹកផ្ទះដោយសារការឆ្លងវីរុសកូរូណាថ្មី ឬស្ថានភាពដែលមានជំងឺផ្តាសាយស្រដៀងទៅនឹងរោគសញ្ញាវីរុសកូរូណាថ្មី ហើយពួកគេមិនបានបដិសេធចំពោះការផ្តល់ជូនការងារចាប់តាំងពីពួកគេបានចាប់ផ្តើមនៅផ្ទះដោយសារតែការឈឺនេះ ឬ

(C) ពួកគេត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យឬការថែទាំសុខភាពនៅស្ថាប័នផ្សេងទៀត ដោយសារតែការឆ្លងវីរុសកូរូណាថ្មីនេះ ប៉ុន្តែមានរយៈពេលតិចជាងកន្លះសប្តាហ៍ ហើយពួកគេមិនបានបដិសេធចំពោះការផ្តល់ជូនការដើម្បីធ្វើការនៅសប្តាហ៍នោះទេ។

(b) ប្រជាពលរដ្ឋមិនអាចធ្វើការក្នុងមួយសប្តាហ៍បានទេ ប្រសិនបើពួកគេត្រូវបានគេផ្តល់ជូនការងារសមរម្យ ហើយមិនទទួលយកដោយសារតែពួកគេឈឺដោយមានការឆ្លងវីរុសកូរូណាថ្មី ឬស្ថានភាពដែលមានជំងឺផ្តាសាយស្រដៀងទៅនឹងរោគសញ្ញាវីរុសកូរូណាថ្មី។

(4) <u>ការស្វែងរកការងារយ៉ាងសកម្ម</u>– ORS 657.155(1)(c) ហើយច្បាប់សហព័ន្ធតម្រូវឱ្យប្រជាពលរដ្ឋអាចស្វែងរកការងារយ៉ាងសកម្ម ដើម្បីទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងភាពគ្មានការងារធ្វើ។
**ច្បាប់ស្តីពីការឆ្លើយតបនឹងការឆ្លងវីរុសកូរូណាលើកដំបូងរបស់ក្រុមគ្រួសារសហព័ន្ធ (The federal Families First Coronavirus Response Act) អនុញ្ញាតឱ្យរដ្ឋនានាកែសម្រួលច្បាប់ស្តីពីធានារ៉ាប់រងភាពគ្មានការងារធ្វើរបស់ពួកគេជាបណ្តោះអាសន្នដែលទាក់ទងនឹងតម្រូវការទាមទារស្វែងរកការងារដោយផ្អែកលើមូលដ្ឋានគ្រាអាសន្ន ដើម្បីឆ្លើយតបទៅនឹងការរីករាលដាលនៃវីរុស COVID-19 (ផ្នែក 4102(b))។ ដោយសារមានសារៈសំខាន់ខ្លាំងចំពោះសុខភាពសាធារណៈ និងសុវត្ថិភាពនៃការកាត់បន្ថយការរីករាលដាលនៃវីរុស COVID-19 នោះ វិធានការគ្រប់គ្រងការឆ្លងវីរុសដោយនៅឃ្លាតឆ្ងាយពីគ្នាត្រូវបានថែរក្សា។ ដូច្នេះការចាប់ផ្តើមមានប្រសិទ្ធភាពចំពោះសប្តាហ៍បញ្ចប់នៅថ្ងៃទី 28 ខែមីនា ឆ្នាំ 2020 ទោះបីជាជាមានបទបញ្ញា OAR 471-030-0036 ក៏ដោយ លើកលែងតែមានការជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរបៀបផ្សេងទៀតដោយនាយកដ្ឋានការងារនោះ ប្រជាពលរដ្ឋនឹងត្រូវបានគិតពិចារណាថាស្វែងរកការងារយ៉ាងសកម្មសម្រាប់គោលបំណងនៃបទបញ្ញា ORS 657.155 ប្រសិនបើពួកគេមានបំណងចង់ស្វែងរកធ្វើការនៅពេលមានការប្រកាសអាសន្នរបស់រដ្ឋនិងមូលដ្ឋានដែលទាក់ទងទៅនឹងការឆ្លងវីរុសកូរូណានេះ ផុតសុពលភាព ឬបើមិនដូច្នេះទេ នឹងលែងមានប្រសិទ្ធភាពទៀតទេ។**

(5) <u>អាចមានការងារ</u>– ORS 657.155(1)(c) ហើយច្បាប់សហព័ន្ធតម្រូវឱ្យប្រជាពលរដ្ឋអាចមានការងារ ដើម្បីទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងភាពគ្មានការងារធ្វើ។ ប្រជាពលរដ្ឋមិនត្រូវបានគេចាត់ទុកថា មិនអាចមានការងារបានទេ ដោយសារៈ

(a) ពួកគេកំពុងស្នាក់នៅក្នុងផ្ទះរបស់ពួកគេ ឬត្រូវស្ថិតនៅដាច់ដោយឡែកពីគ្នាដោយសារតែមានហានិភ័យនៃការប៉ះពាល់ឬការរាលដាលនៃវីរុសកូរូណាថ្មីតាមការណែនាំរបស់អ្នកផ្តល់សេវាថែទាំសុខភាពឬតាមការផ្តល់ដំបូន្មានដែលចេញដោយមន្ត្រីសុខាភិបាលរដ្ឋឬតាមការណែនាំរបស់មន្ត្រីរដ្ឋាភិបាល ទោះបីជានិយោជកមានការងារសម្រាប់ពួកគេក៏ដោយ ក៏ពួកគេអាចអនុវត្តការងារតាមរបៀបផ្សេងទៀតផងដែរ។

(b) ពួកគេនៅផ្ទះតែម្នាក់ឯង ពីព្រោះពួកគេខ្វះការមើលថែទាំកុមារឬកុមារៗ ដោយសារតែការបិទឬការកាត់បន្ថយសាលារៀនឬកន្លែងមើលថែទាំកុមារពេលថ្ងៃ។

(c) ពួកគេនៅផ្ទះមើលថែទាំសមាជិកគ្រួសារ ដោយសារតែមានផលប៉ះពាល់ពីវីរុសកូរូណាថ្មី ឬ

(d) **តាមធម្មតាពួកគេធ្វើការតិចជាងការងារពេញម៉ោង ហើយអាចមានការងារតិចជាងការងារពេញម៉ោង។**

(6) **ORS 657.315(2) អនុញ្ញាតឱ្យមានការលើកលើងពីការទទួលបានមកវិញនូវការទូទាត់ប្រាក់លើសកំណត់ ប្រសិនបើការទូទាត់ប្រាក់លើសកំណត់មិនបានបង្កឡើងតាមរបៀបណាមួយដោយអ្នកទាមទារសំណង ហើយបើការទទួលបានមកវិញអាចជំទាស់នឹងសមធម៌និងមនសិការល្អ។ ទោះបីជាបទបញ្ញា OAR 471030-0053 សម្រាប់អត្ថប្រយោជន៍ដែលបានបង់ជូនសម្រាប់សប្តាហ៍នានាដែលចាប់ផ្តើមពីសប្តាហ៍បញ្ចប់នៅថ្ងៃទី 28 ខែមីនា ឆ្នាំ 2020 ដោយសារតែលក្ខខណ្ឌសេដ្ឋកិច្ចដែលកើតមានឡើងដោយវីរុសកូរូណា និងការចាត់វិធានការដើម្បីកាត់បន្ថយការរីករាលដាលនោះក៏ដោយ ក៏វាអាចជំទាស់នឹងសមធម៌និងមនសិការល្អ ដើម្បីទទួលបានមកវិញនូវការទូទាត់ប្រាក់លើសកំណត់ទាំងនេះផងដែរ។ កិច្ចខិតខំប្រឹងប្រែងទទួលបានមកវិញអាចបន្តដំណើរការឡើងវិញបន្ទាប់ពីការប្រកាសអាសន្នដែលទាក់ទងនឹងការឆ្លងវីរុសកូរូណានេះ ផុតសុពលភាព ឬបើមិនដូច្នោះទេ វាលែងមានប្រសិទ្ធភាពទៀតទេ។**